## ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាបុណ្យហែស្លឹក
## ព្រះសហគមន៍ពោធិបាន ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៩
## ព្រះយេស៊ូយាងមកដើម្បីឲ្យយើងទទួលជីវិត

**អត្ថបទទី១៖ អេសាយ ៥០,៤-៧**

ព្រះជាអម្ចាស់បង្រៀនខ្ញុំឲ្យនិយាយពាក្យសម្ដីជាសាវ័ក ដើម្បីឲ្យខ្ញុំលើកទឹកចិត្ត មនុស្សដែលអស់សង្ឃឹម។ អស ៥០,៤

**អត្ថបទទី២៖ ភីលីព ២,៦-១១**

ព្រះអង្គបានដាក់ខ្លួន ធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គត គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង។ ភីល ២,៨

**ដំណឹងល្អ៖ លូកា ២២,១៤-៥៦**

ស្ត្រីបម្រើម្នាក់ឃើញគាត់អង្គុយនៅមុខពន្លឺភ្លើង សម្លឹងមើលគាត់ហើយពោលថា៖ "ម្នាក់នេះជាបក្សពួករបស់យេស៊ូ!"។ លក ២២,៥៦

បងប្អូនជាទីស្រឡាញ់!

នៅពេលយើងហែស្លឹក ប្រជាជនស្រែកថា "**ជយោព្រះយេស៊ូ! ជយោព្រះរាជវង្សព្រះបាទដាវីឌ**" តែអត្ថបទដែលយើងបានស្ដាប់អំបាញ់មិញ មនុស្សដែលស្រែកថាជយោព្រះយេស៊ូហ្នឹង គេស្រែកថាឆ្កាងទៅៗដើម្បីសម្លាប់ព្រះយេស៊ូ។ អ្វីដែលយើងស្ដាប់ថ្ងៃនេះ ជារឿងមួយដែលណែនាំឲ្យយើងចូលនៅក្នុងទុក្ខលំបាករបស់ព្រះយេស៊ូ ប៉ុន្តែចូលនៅក្នុងទុក្ខលំបាកនៃជីវិតយើងទាំងឡាយដែរ។ ថ្ងៃនេះជាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៩ សម្រាប់ជនជាតិខ្មែរជាថ្ងៃទីមួយនៃពិធីបុណ្យចូលឆ្នាំប្រពៃណី ប៉ុន្តែថ្ងៃនេះសម្រាប់ព្រះសហគមន៍កម្ពុជាជាពេលវេលាមួយដើម្បីនឹករលឹកដល់លោកអភិបាល **ឆ្នារ សាឡាស់** ជាបូជាចារ្យខ្មែរដែលបានទទួលអគ្គសញ្ញាតែងតាំងជាអភិបាល នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥។ យើងដឹងហើយដូចរឿងរបស់ព្រះយេស៊ូ នៅថ្ងៃទទួលអំណរសប្បាយជាអភិបាលព្រះសហគមន៍ បីថ្ងៃក្រោយមកគឺថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមខ្មែរក្រហមចូលនៅក្នុងទីក្រុងភ្នំពេញនិងបណ្ដេញទាំងប្រជាជននៅក្នុងទីក្រុងភ្នំពេញ បណ្ដេញទាំងលោកអភិបាល បណ្ដេញទាំងលោកបូជាចារ្យដែលនៅសល់ប៉ុន្មានអង្គ ឲ្យធ្វើដំណើរហើយនៅពេលនោះលោកអភិបាល **ឆ្នារ សាឡាស់** ជាមួយ**សាឡឹម** ដែលជាប្អូនរបស់គាត់ជាមួយ**សម្រើន** បានធ្វើដំណើរដល់តាំងគោក។ លោកសាសនទូតដែលនៅសល់ប៉ុន្មាន មានលោកតាប៉ុងសូ មានលោកអភិបាលអ៊ីវ លោកអភិបាលអេមីល មានលោកតាវើណេ គេបានទៅស្ថានទូតបារាំងប៉ុន្មានខែរហូតគេបណ្ដេញចេញពីប្រទេសកម្ពុជា។

ដូច្នេះយើងឃើញទុក្ខលំបាករបស់ព្រះយេស៊ូ ទុក្ខលំបាករបស់ព្រះសហគមន៍ធ្វើដំណើរជាមួយគ្នា នៅថ្ងៃនេះយើងមានអំណរសប្បាយព្រះយេស៊ូទៅជាព្រះរាជវង្សព្រះបាទដាវីឌ ជាព្រះមហាក្សត្ររបស់យើង។ ថ្ងៃនេះ យើងមានអំណរសប្បាយលោក ឆ្មារ សាឡាស់ ជាអភិបាលថ្មីរបស់ព្រះសហគមន៍កាតូលិកកម្ពុជា ៣ថ្ងៃក្រោយមកគេចាប់គាត់ដើម្បីចូលនៅក្នុងពេលវេលាខ្មៅងងឹតរួមជាមួយប្រជាជនខ្មែរទាំងមូល អស់រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ ព្រះយេស៊ូក៏ដូចគ្នាដែរ ព្រះយេស៊ូបានខិតខំអស់ពីសមត្ថភាព ដើម្បីប្រកាសដំណឹងល្អ ដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមក មានន័យថាដើម្បីឲ្យអ្នកជម្ងឺបានជាសះស្បើយ ដើម្បីឲ្យអ្នកក្រីក្រមានសេចក្តីសង្ឃឹម ដើម្បីមនុស្សវង្វេងផ្លូវរស់នៅក្នុងងងឹតអាចឃើញពន្លឺនៅក្នុងជីវិតគេ។ ប៉ុន្តែលោកពីឡាតដែលត្រូវកាត់ក្តីព្រះយេស៊ូ គាត់យល់ព្រះយេស៊ូជាអ្នកណា គាត់យល់ព្រះយេស៊ូជាមនុស្សសុចរិត គាត់មើលមិនឃើញអំពីរបៀបកាត់ក្តីព្រះយេស៊ូនិងសម្លាប់ព្រះយេស៊ូដូចគេស្នើសុំ ព្រះយេស៊ូបានធ្វើអ្វីខុស ដើម្បីឲ្យមហាជនស្រែកយ៉ាងខ្លាំងថាឆ្កាងទៅៗ និងសុខចិត្តដោះលែងបាំណាបាស់ពីមន្ទីរឃុំឃាំងដែលជាឃាតករ។ លោកពីឡាតគាត់ដឹងថា ព្រះយេស៊ូមិនមែនមនុស្សធម្មតាទេ ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ មហាជនមានឱកាសច្រើនដើម្បីឃើញសញ្ញាប្លែកៗ ព្រះយេស៊ូមិនមែនមនុស្សធម្មតាទេ ក្រុមបូជាចារ្យនិងក្រុមផារីស៊ីប៉ុន្មានដងគេបានឃើញព្រះយេស៊ូបានព្យាបាល ព្រះយេស៊ូបានណែនាំឲ្យមនុស្សមានជីវិត ឡាសារបានរស់ឡើងវិញមិនមែនមនុស្សធម្មតាទេ។ ប៉ុន្តែជាមូលហេតុគេភ័យ ដោយសារព្រះយេស៊ូធ្លាប់មានព្រះបន្ទូលថា "**ខ្ញុំជាព្រះបុត្រារបស់ព្រះជាម្ចាស់ ខ្ញុំជាព្រះជាម្ចាស់**" គេមិនអាចទទួលបានទេ ព្រះយេស៊ូជាអ្នកណា ព្រះយេស៊ូជាកូនរបស់នាងម៉ារីនិងលោកយ៉ូសែប ព្រះយេស៊ូជាព្រះជាម្ចាស់យ៉ាងម៉េចបាននិយាយដូច្នេះដូចជាប្រមាទព្រះជាម្ចាស់ ហេតុនេះហើយត្រូវតែសម្លាប់ព្រះយេស៊ូ។

ប៉ុន្តែ យើងដឹងហើយគេចង់សម្លាប់ព្រះយេស៊ូមូលហេតុតែមួយ គឺគេច្រណែន គេខ្លាច គេឃើញមានប្រជាជនជាច្រើនដើរតាមព្រះយេស៊ូ នៅពេលព្រះយេស៊ូមានព្រះបន្ទូលជាសេចក្តីពិតដោយសារព្រះយេស៊ូជាសេចក្តីពិត និងព្រះយេស៊ូចង្អុលគេប៉ុន្មានដងប៉ុន្មានសារ ចង្អុលគណៈផារីស៊ីមានពុតអើយ ឲ្យយើងធ្វើតាមវិន័យ ឲ្យយើងគោរពថ្ងៃសប្ប័ទប៉ុន្តែនៅក្នុងដួងចិត្តគេមានអំពើបាបច្រើនណាស់ មានគំនិតអាក្រក់ច្រើនណាស់។ ព្រះយេស៊ូយាងមកដើម្បីឲ្យយើងទទួលជីវិតតាមពិតភាពងងឹតជាអ្វីដែលចេញពីចិត្តគំនិតរបស់មនុស្ស ព្រោះព្រះយេស៊ូមិនស្លាប់ដោយសារព្រះជាម្ចាស់ ព្រះយេស៊ូស្លាប់ដោយសារមនុស្ស។ លោកយូដា ជាឧបករណ៍នៃមារសាតាំងដើម្បីចាប់ព្រះយេស៊ូ និងមហាជនតាមពិតគេមិនចង់សម្លាប់ព្រះយេស៊ូទេ ប៉ុន្តែមានអ្នកបង្ខំនិងមហាជនដើរតាមគេដោយសារគាត់ខ្លាច គាត់អត់មានសេចក្តីក្លាហ៊ាន លោកសិលាគាត់មិនចង់ក្បត់

ព្រះយេស៊ូទេ ប៉ុន្តែលោកសិលាបានបដិសេធ៣ដង ទោះបីព្រះយេស៊ូបានប្រគល់ព្រះរាជ្យរបស់ព្រះជាម្ចាស់និងព្រះសហគន៍ឲ្យគាត់ ទោះបីព្រះយេស៊ូបានប្រគល់តួនាទីឲ្យបម្រើព្រះសហគមន៍នឹង ប៉ុន្តែគាត់ភ័យ គាត់ខ្លាច ជំនឿរបស់គាត់អត់ទាន់ល្មមទេ ព្រះវិញ្ញាណដ៏វិសុទ្ធអត់ទាន់យាងមកដ៏ពេញលក្ខណៈ ដូច្នេះគាត់បដិសេធ៣ដង ខ្ញុំមិនស្គាល់ ខ្ញុំមិនស្គាល់ ខ្ញុំមិនស្គាល់ព្រះយេស៊ូទេ។ ក្រោយមកគាត់សោកស្តាយ ក្នុងសន្តលូកាដែលយើងស្តាប់ថ្ងៃនេះ "**ព្រះយេស៊ូទតមើលគាត់នៅពេលមាន់បានរងាវហើយ**" មើលគាត់យ៉ាងច្បាស់ដោយភ្នែកអាណិតមេត្តា ធ្វើឲ្យលោកសិលារត់ទៅយំ ដោយសារគាត់យល់ថាគាត់បានបដិសេធមិនស្គាល់ព្រះយេស៊ូ គាត់បានក្បត់ព្រះយេស៊ូយ៉ាងជាក់ស្តែង។ ដូច្នេះ ថ្ងៃនេះយើងនឹកឃើញដល់ជីវិតរបស់យើងដែរ ដែលមានទុក្ខលំបាក ដែលមានការតស៊ូចូលនៅក្នុងសោយទិវង្គតរបស់ព្រះយេស៊ូ រួមស្លាប់ជាមួយព្រះយេស៊ូថ្ងៃនេះ រួមស្លាប់អំពីអំពើបាបរបស់យើងអំពីភាពងងឹតនៅក្នុងជីវិតរបស់យើង។ ប៉ុន្តែ ខ្ញុំសង្ឃឹមយើងទាំងអស់គ្នាយើងអាចនិយាយថា ពិតមែនមនុស្សនេះជាព្រះបុត្រារបស់ព្រះជាម្ចាស់ ជាពាក្យដែលយើងបានស្តាប់ពីមហាជននិងពីទាហាន មនុស្សនេះពិតជាសុចរិតមែន នៅពេលព្រះយេស៊ូសោយទិវង្គតហើយ។

ដូច្នេះ ថ្ងៃនេះយើងអត់ទាន់នឹកឃើញដល់ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ប៉ុន្តែថ្ងៃនេះយើងនឹកឃើញដល់ទុក្ខលំបាករបស់យើង ដល់ភាពងងឹតរបស់យើង។ យើងមើលព្រះយេស៊ូនៅលើឈើឆ្កាងដែលសោយទិវង្គត រួមជាមួយទាហាន រួមជាមួយមហាជន រួមជាមួយគ្រីស្តទូត រួមជាមួយលោកសិលា និងក្រុមគ្រីស្តទូតទាំងឡាយ យើងអាចនិយាយថា ពិតមែនព្រះយេស៊ូមនុស្សសុចរិត។ អាម៉ែន៕